**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ពិព័រណ៍ការងារ និងមគ្គុទេសក៍អាជីព ឆ្នាំ២០២៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់គ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន អង្គការជាតិ អន្តរជាតិ សិស្ស និស្សិត អ្នកស្វែងរកការងារ និងសាធារណជនជ្រាបថា ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) រាជធានីភ្នំពេញ និងអង្គការអន្តរជាតិខាងការងារ (ILO) នឹងរៀបចំ «**ពិព័រណ៍ការងារ និងមគ្គុទេសក៍អាជីព ឆ្នាំ២០២៤**» ដែលនឹងប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ គឺចាប់ពីថ្ងៃទី៩-១០ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១៧:០០នាទីល្ងាច នៅអគារ KAMPUS ជិតស្ពានអាកាសក្បាលថ្នល់។

ពិព័រណ៍ការងារ និងមគ្គុទេសក៍អាជីពនេះ ជាវេទិកាជួបជុំគ្នានៅមួយកន្លែងដោយផ្តល់ភាពងាយស្រួលសម្រាប់និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ព្រមទាំងអ្នកស្វែងរកការងារ និងជាសិក្ខាសាលាចែករំលែកបទពិសោធន៍ ការប្រឹក្សាយោបល់ការងារនិងអាជីព និងការត្រៀមខ្លួនចូលបម្រើការងារ ដោយមានវាគ្មិនដែលមានបទពិសោធន៍ច្រើនឆ្នាំក្នុងទីផ្សារការងារ។ ព្រឹត្តិការណ៍នេះ នឹងមានក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលធំៗ ចូលរួមតាំងបង្ហាញអំពីតម្រូវការជ្រើសរើសកម្លាំងពលកម្ម កម្មសិក្សាការងារ និងផ្សព្វផ្សាយនូវកម្មវិធីសិក្សា និងកម្មវិធីអភិវឌ្ឍជំនាញគ្រប់ប្រភេទ ដើម្បីទាក់ទាញយុវជនដែលកំពុងស្វែងរកការងារធ្វើ ចូលរួមដាក់ពាក្យចូលបម្រើការងារ និងចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សានានាផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខទូរស័ព្ទ ០១៧ ៤៦៧ ៤២៣ / ០១៧ ៨៧១ ៨០៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន អង្គការជាតិ អន្តរជាតិ សិស្ស និស្សិត អ្នកស្វែងរកការងារ និងសាធារណជន ជ្រាបជាព័ត៌មាន និងចូលរួមឱ្យបានច្រើនកុះករ។

ថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤